# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៩ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១._**

អនុក្រឹត្យនេះ មានគោលបំណងអនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២._**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគម្រោងវិនិយោគដែលត្រូវបានចុះបញ្ជីទទួលស្គាល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬដោយអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

**មាត្រា៣.-**

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចតទៅ៖

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សរសេរជាអក្សរកាត់ថា ក.អ.ក. សំដៅដល់ស្ថាប័នប្រតិបត្តិបំពេញមុខងារជាសេនាធិការ និងជាច្រកចេញចូលតែមួយរបស់រាជរដ្ឋាភិបាលលើបេសកកម្មដឹកនាំនិងគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ការវិនិយោគឯកជន និងតំបន់សេដ្ឋកិច្ចពិសេស។

អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត សរសេរជាអក្សរកាត់ថា អ.គ.វ.រ.ខ. សំដៅដល់អង្គភាពបំពេញមុខងារជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្ត ដើម្បីជាយន្តការក្នុងការពិនិត្យសម្រេចលើការវិនិយោគឯកជន និងការដោះស្រាយវិវាទពាក់ព័ន្ធនឹងគម្រោងវិនិយោគ។

ក្រុមសកម្មភាពវិនិយោគ ទី១ សរសេរជាពាក្យកាត់ថា ក្រុម ១ សំដៅដល់ក្រុមសកម្មភាពវិនិយោគដែលមានចែងក្នុងផ្នែកទី១ ឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ និងជាក្រុមសកម្មភាពវិនិយោគដែលប្រើប្រាស់បច្ចេកវិទ្យាខ្ពស់ ឬស្ថិតក្នុងវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល។

ក្រុមសកម្មភាពវិនិយោគ ទី២ សរសេរជាពាក្យកាត់ថា ក្រុម ២ សំដៅដល់ក្រុមសកម្មភាពវិនិយោគដែលមានចែងក្នុងផ្នែកទី២ ឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ និងជាក្រុមសកម្មភាពវិនិយោគដែលប្រើប្រាស់បច្ចេកវិទ្យាមធ្យម។

ក្រុមសកម្មភាពវិនិយោគ ទី៣ សរសេរជាពាក្យកាត់ថា ក្រុម ៣ សំដៅដល់ក្រុមសកម្មភាពវិនិយោគដែលមានចែងក្នុងផ្នែកទី៣ ឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ និងជាក្រុមសកម្មភាពវិនិយោគដែលប្រើប្រាស់បច្ចេកវិទ្យាទាប។

គម្រោងវិនិយោគ សំដៅដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងគម្រោងវិនិយោគដែលទទួលបានត្រឹមតែការធានាលើការវិនិយោគ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សរសេរជាអក្សរកាត់ថា គ.ល.គ. សំដៅដល់គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីពី ក.អ.ក. ឬ អ.គ.វ.រ.ខ.។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ សំដៅដល់ គ.ល.គ. ដែលបានលក់ឬបានផ្ទេរសមាមាត្រណាមួយនៃផលិតផលរបស់ខ្លួនទៅឱ្យអ្នកទិញឬអ្នកទទួលនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រ សំដៅដល់ គ.ល.គ. ដែលផលិតផលរបស់ខ្លួនក្នុងសមាមាត្រណាមួយ ត្រូវផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើទីផ្សារក្នុងស្រុក សំដៅដល់ គ.ល.គ. ដែលមិនបម្រើឱ្យការនាំចេញ។

គម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សរសេរជាអក្សរកាត់ គ.ព.គ.ល.គ. សំដៅដល់ការពង្រីកនៃ គ.ល.គ. ដែលធ្វើឡើងតាមរូបភាពណាមួយ មានជាអាទិ៍ ការពង្រីកផលិតកម្មដែលមានស្រាប់ ការពង្រីកតាមរយៈការធ្វើពិពិធកម្មមុខសញ្ញាផលិតកម្មដែលស្ថិតក្នុងខ្សែសង្វាក់ផលិតផលជាមួយគ្នា ការពង្រីកតាមរយៈការបំពាក់បច្ចេកវិទ្យាទំនើបថ្មីដែលលើកកម្ពស់ផលិតភាពឬការពារបរិស្ថាន ការពង្រីកហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យសេវាទូរគមនាគមន៍មូលដ្ឋាន ឬការពង្រីកក្រោមរូបភាពផ្សេងទៀត។

គម្រោងវិនិយោគដែលទទួលបានត្រឹមតែការធានាលើការវិនិយោគ សរសេរជាអក្សរកាត់ គ.ធ.វ. សំដៅដល់គម្រោងវិនិយោគដែលបានចុះបញ្ជីនៅ ក.អ.ក. ឬ អ.គ.វ.ខ. ដោយមានបញ្ជាក់ច្បាស់ថាជា គ.ធ.វ. ប៉ុន្តែពុំទទួលបានការលើកទឹកចិត្តផ្នែកសារពើពន្ធ។

ថ្ងៃធ្វើការ សំដៅដល់ថ្ងៃប្រតិទិនដែលជាថ្ងៃធ្វើការជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា។

ធាតុចូលផលិតកម្ម សំដៅដល់វត្ថុធាតុដើម ផលិតផលពាក់កណ្ដាលសម្រេច និងសម្ភារៈបន្ទាប់បន្សំ រួមទាំងទំនិញដែលត្រូវបំប្លែងនៅក្នុងកិច្ចដំណើរការផលិតកម្ម លើកលែងតែផលិតផលតេលសិលានិងគ្រឿងបន្លាស់យានយន្ត។

នីតិបុគ្គលសញ្ជាតិខ្មែរ សំដៅដល់ក្រុមហ៊ុនដែលមានទីកន្លែងអាជីវកម្មនិងបានធ្វើការចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលមានភាគហ៊ុនចាប់ពី ៥១ (ហាសិបមួយ) ភាគរយ ក្នុងក្រុមហ៊ុន ត្រូវបានកាន់កាប់ដោយបុគ្គលដែលមានសញ្ជាតិខ្មែរ។

បរិក្ខារសំណង់ សំដៅដល់បរិក្ខារដែលត្រូវបានផ្គុំ បង្កើត ឬផលិតឡើង ដើម្បីប្រើប្រាស់ ឬបំពាក់ភ្ជាប់នឹងសំណង់ដើម្បីបង្កើនគុណភាព ផាសុកភាព និងភាពងាយស្រួលនៃការប្រើប្រាស់សំណង់ មានជាអាទិ៍ អំពូលភ្លើង ខ្សែភ្លើង ខ្សែកាបអុបទិក ឡាវ៉ាបូ រ៉ូប៊ីណេ ផើងងូតទឹក ជណ្ដើរយន្ត ទុយោ និងម៉ាស៊ីនត្រជាក់។ ចំពោះការលើកទឹកចិត្តសម្រាប់ការនាំចូលម៉ាស៊ីនត្រជាក់ដូចមានចែងក្នុងអនុក្រឹត្យនេះ គឺសម្រាប់តែបម្រើឱ្យ គ.ល.គ. ក្នុងវិស័យកម្មន្តសាល។ ចំពោះការនាំចូលម៉ាស៊ីនត្រជាក់សម្រាប់សកម្មភាព ឬគម្រោងវិនិយោគក្នុងវិស័យជាក់លាក់ណាមួយក្រៅពីវិស័យកម្មន្តសាល នឹងទទួលបានការលើកទឹកចិត្តដែលនឹងត្រូវកំណត់នៅក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឬនៅក្នុងអនុក្រឹត្យដោយឡែក។

បុគ្គល សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គល។

បញ្ជីអវិជ្ជមាន សំដៅដល់បញ្ជីគម្រោងវិនិយោគដែលកំណត់នៅក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ និងដែលតាមមាត្រា១២ នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ជាបញ្ជីនៃសកម្មភាពវិនិយោគដែលមិនអាចចាត់ទុកថាជា គ.ល.គ.។

បញ្ជីបែងចែកក្រុមនៃសកម្មភាពវិនិយោគ សំដៅដល់បញ្ជីសកម្មភាពវិនិយោគ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ និងជាបញ្ជីនៃប្រភេទក្រុមសកម្មភាពវិនិយោគ ទី១ ទី២ និងទី៣ ដែលត្រូវបានបែងចែកទៅតាមទិសដៅគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងកម្រិតបច្ចេកវិទ្យា។

ពន្ធលើប្រាក់ចំណូលដែលទទួលបានការលើកទឹកចិត្ត សំដៅដល់ពន្ធដែលអនុវត្តចំពោះប្រាក់ចំណូលជាប់ពន្ធពីសកម្មភាពអាជីវកម្មរបស់ គ.ល.គ.។ ប្រាក់ចំណូលជាប់ពន្ធសំដៅដល់ប្រាក់ចំណូលសុទ្ធដែលគណនាទៅតាមបទប្បញ្ញត្តិស្ដីពីពន្ធដារជាធរមាន។

វិញ្ញាបនបត្រចុះបញ្ជី សំដៅដល់វិញ្ញាបនបត្រដែលចេញដោយ ក.អ.ក. ឬ អ.គ.វ.ខ. បញ្ជាក់ពីការទទួលស្គាល់គម្រោងវិនិយោគ។

វិនិយោគិន សំដៅដល់បុគ្គលអនុវត្តគម្រោងវិនិយោគដែលបានចុះបញ្ជីនៅ ក.អ.ក.ឬ អ.គ.វ.ខ.។

**សកម្មភាពវិនិយោគ** សំដៅដល់សកម្មភាពធុរកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជាដែលត្រូវបានបង្កើតឡើង ឬត្រូវបានទិញយក ឬត្រូវបានលក់ ឬត្រូវបានធ្វើអនុប្បទាន ឬត្រូវបានពង្រីក ឬត្រូវបានរួមបញ្ចូលគ្នា និងត្រូវបានអនុញ្ញាតជាលាយលក្ខណ៍អក្សរដោយស្ថាប័នទទួលបន្ទុក ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មជ្ឈមណ្ឌលឡូជីស្ទិក (ឬ ភ័ស្តុភារកម្ម)** គឺសំដៅទៅលើមជ្ឈមណ្ឌលប្រមូល រក្សាទុក និងចែកចាយទំនិញតាមការដឹកជញ្ជូន ឬក្នុងរួមទាំងសេវាឡូជីស្ទិក (ឬ ភ័ស្តុភារកម្ម)ដែលមានតម្លៃបន្ថែម (Value Added Service) ដូចជា÷ សេវាលើកដាក់, ផ្ទេរ-ផ្ទុកទំនិញ, ផ្គុំទំនិញ, ធ្វើចំណាត់ថ្នាក់, វេចខ្ចប់, បង្រួមកញ្ចប់ទំនិញទៅក្នុងកុងតឺន័រ, ការបំពេញបែបបទគយ និងការដំណើរការព័ត៌មានសម្រាប់រំហូរទំនិញ។

**សំណើសុំចុះបញ្ជីគម្រោងវិនិយោគ** សំដៅដល់សំណើដែលបានដាក់ជូន **ក.អ.ក.** ឬដាក់ជូន **អ.គ.វ.ស.ខ.** ដោយបុគ្គលណាមួយក្នុងគោលបំណងបង្កើត គ.ល.គ. និងគ.ធ.វ.។ សំណើនេះអាចរាប់បញ្ចូលដំណាក់កាលមួយឬច្រើន ដោយរួមបញ្ចូលទាំងសំណើសុំពង្រីក គ.ល.គ.។

**សម្ភារៈបរិក្ខារផលិតកម្ម** សំដៅដល់គ្រឿងចក្រ គ្រឿងម៉ាស៊ីន និងឧបករណ៍ផ្សេងៗ សម្រាប់ប្រើប្រាស់ជាមូលដ្ឋានសំខាន់ក្នុងខ្សែច្រវាក់ផលិតកម្ម លើកលែងតែយានយន្ត។

**សម្ភារៈសាងសង់** សំដៅដល់សម្ភារៈសំណង់ដែលបានបំប្លែងឬបានប្រើប្រាស់ទាំងស្រុងនៅក្នុងការសាងសង់សំណង់នានា រួមបញ្ចូលទាំង បរិក្ខារសំណង់ សម្រាប់ គ.ល.គ. ប្រើប្រាស់ ដើម្បីដំណើរការសកម្មភាពវិនិយោគរបស់ខ្លួន នៅក្នុងដំណាក់កាលសាងសង់ដំបូងឬពង្រីក។ សម្ភារៈសំណង់ សំដៅដល់វត្ថុធាតុដើមសម្រាប់ធ្វើការលាយផ្សំ ផ្គុំ ឬប្រើប្រាស់ជាគ្រឿងផ្គុំសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ មានជាអាទិ៍ ខ្សាច់ ថ្ម ក្រួស ស៊ីម៉ង់ត៍ ដែកកញ្ចក់ ដីឥដ្ឋ សេរ៉ាមិក ឈើ។

បរិក្ខារសំណង់ សម្ភារៈសាងសង់ និងសម្ភារៈបរិក្ខារផលិតកម្ម ដូចមានចែងក្នុងមាត្រានេះត្រូវមានលក្ខខណ្ឌបច្ចេកទេសនិងបរិមាណសមស្របទៅនឹងគម្រោងវិនិយោគ។

**អ្នកដាក់ពាក្យសុំ** សំដៅដល់បុគ្គលដាក់សំណើសុំចុះបញ្ជីគម្រោងវិនិយោគនៅ **ក.អ.ក.** ឬ **អ.គ.វ.ស.ខ.**។

**ទុនវិនិយោគ** សំដៅដល់តម្លៃវិនិយោគដែលបង្ហាញជារូបិយវត្ថុ ឬរូបិយបណ្ណបរទេស ដោយមិនរាប់បញ្ចូលតម្លៃដីធ្លី និងទុនបង្វិល។

**ទុនពង្រីក គ.ល.គ.** សំដៅដល់តម្លៃវិនិយោគបន្ថែមលើ **គ.ល.គ.** ដែលមានស្រាប់ ដែលត្រូវបានប្រើប្រាស់សម្រាប់តែការវិនិយោគលើសម្ភារៈសាងសង់និងសម្ភារៈបរិក្ខារផលិតកម្មថ្មី។

**សំណុំពាក្យសុំចុះបញ្ជីគម្រោងវិនិយោគ** សំដៅដល់ពាក្យសុំចុះបញ្ជី ដូចមានទម្រង់ក្នុងឧបសម្ព័ន្ធទី៥ ឧបសម្ព័ន្ធទី៦ និងឧបសម្ព័ន្ធទី៧ នៃអនុក្រឹត្យនេះ និងឯកសារគាំទ្រដល់សំណើសុំចុះបញ្ជី។

**សេវាកម្មវិជ្ជាជីវៈ** សំដៅដល់សេវាទាំងឡាយ ដែលមានជាអាទិ៍ សេវាកម្មច្បាប់ ហិរញ្ញវត្ថុ គណនេយ្យ សវនកម្ម ទីប្រឹក្សាសារពើពន្ធ ស្ថាបត្យកម្ម វិស្វកម្ម សេវាកម្មបច្ចេកវិទ្យាព័ត៌មាន ផ្សព្វផ្សាយព័ត៌មាន ផ្សព្វផ្សាយពាណិជ្ជកម្ម សេវាកម្មគ្រប់គ្រង។

**អ្នកតំណាងដែលមានសិទ្ធិ** សំដៅដល់អ្នកតំណាងស្របច្បាប់ដែលបានទទួលសិទ្ធិពីរូបវន្តបុគ្គលឬនីតិបុគ្គលដែលអនុវត្តគម្រោងវិនិយោគ និងមានសិទ្ធិសម្រេចតាមកម្រិតសិទ្ធិដែលបានប្រគល់ជូនតាមរយៈលិខិតផ្ទេរសិទ្ធិ។

ឯកសារគាំទ្រ សំដៅដល់ឯកសារដែលត្រូវដាក់ជាមួយសំណើសុំចុះបញ្ជីគម្រោងវិនិយោគឬសំណើសុំដទៃទៀត។

## ជំពូកទី២
## នីតិវិធីនៃការចុះបញ្ជី និងការអនុវត្តគម្រោងវិនិយោគ

**មាត្រា៤.-**

សំណើសុំចុះបញ្ជីគម្រោងវិនិយោគជា គ.ល.ត. ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១- អ្នកដាក់ពាក្យសុំ ត្រូវតែជាបុគ្គលដែលអនុវត្តគម្រោងវិនិយោគ ឬដោយអ្នកតំណាងដែលមានសិទ្ធិ។

២- គម្រោងដែលត្រូវបានស្នើសុំចុះបញ្ជីគម្រោងវិនិយោគជា គ.ល.ត. ត្រូវមានទីតាំងអនុវត្ត និងមានទីស្នាក់ការចុះបញ្ជីច្បាស់លាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៣- គម្រោងដែលបានស្នើសុំចុះបញ្ជីគម្រោងវិនិយោគជា គ.ល.ត. មិនមែនជាសកម្មភាពវិនិយោគដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

បុគ្គលដែលមានបំណងអនុវត្ត គ.ល.ត. ត្រូវដាក់សំណើសុំចុះបញ្ជីគម្រោងវិនិយោគជា គ.ល.ត. ជាលាយលក្ខណ៍អក្សរនៅ ក.អ.ក. ឬ អ.គ.វ.ខ. ដើម្បីទទួលបានការលើកទឹកចិត្ត និងការធានានិងការការពារដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ចំពោះសំណើសុំចុះបញ្ជីគម្រោងវិនិយោគជា គ.ល.ត. ដែលធ្វើឡើងដោយអនុលោមតាមកថាខណ្ឌទី២នៃមាត្រានេះ អ្នកដាក់ពាក្យសុំត្រូវផ្តល់ព័ត៌មានចាំបាច់តាមទម្រង់ពាក្យសុំចុះបញ្ជីជា គ.ល.ត. ដូចមានក្នុងឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យនេះ។

សំណើសុំចុះបញ្ជីគម្រោងវិនិយោគជា គ.ល.ត. ខាងលើនេះ អាចធ្វើឡើងផងដែរតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន។

សំណើសុំចុះបញ្ជីជា គ.ល.ត. ដែលបានបំពេញសព្វគ្រប់ហើយ ត្រូវចុះហត្ថលេខាដោយបុគ្គលដែលត្រូវអនុវត្តគម្រោងវិនិយោគ ឬដោយអ្នកតំណាងដែលមានសិទ្ធិ។

ក្នុងករណីសំណើសុំចុះបញ្ជីជា គ.ល.ត. ត្រូវបានចុះហត្ថលេខាដោយអ្នកតំណាងដែលមានសិទ្ធិ អ្នកតំណាងនោះត្រូវប្រគល់នូវឯកសារដែលបញ្ជាក់អំពីសិទ្ធិជាអ្នកតំណាង និងឯកសារគាំទ្រដែលបញ្ជាក់ពីវិសាលភាពនៃសិទ្ធិសម្រេច។

បុគ្គលមានបំណងធ្វើការវិនិយោគនិងដំណើរការលើសពីសកម្មភាពវិនិយោគមួយឡើងទៅ ត្រូវដាក់សំណើសុំចុះបញ្ជីគម្រោងវិនិយោគជា គ.ល.ត. ដាច់ដោយឡែកពីគ្នាសម្រាប់សកម្មភាពវិនិយោគនីមួយៗ លើកលែងតែសកម្មភាពដែលគាំទ្រឱ្យគម្រោងចម្បងឬគម្រោងពង្រីក។

គម្រោងវិនិយោគដែលត្រូវបានលុបឬបិទឬផ្អាក ដោយពុំបានអនុវត្តតាមនីតិវិធីជាធរមាន មិនត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីគម្រោងវិនិយោគជាថ្មីទេ។

គម្រោងវិនិយោគដែលស្នើសុំចុះបញ្ជីទាំងឡាយណាដែលត្រូវបានរកឃើញថា ធ្លាប់ត្រូវបានលុបឬបិទដោយចេតនាចៀសវាងឬគេចវេះពន្ធ ពុំត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីជា គ.ល.ត.ជាថ្មី។

អ្នកដាក់ពាក្យសុំត្រូវបង់កម្រៃសេវាទៅតាមតារាងតម្លៃសេវាសាធារណៈដែលបានកំណត់។

**មាត្រា៥.-**

សំណើសុំចុះបញ្ជីគម្រោងវិនិយោគជា គ.ព.គ.ល.គ. ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១- អ្នកដាក់ពាក្យសុំ ត្រូវតែជាបុគ្គលដែលអនុវត្តគម្រោងវិនិយោគ ឬដោយអ្នកតំណាងដែលមានសិទ្ធិ។

២- គម្រោងដែលត្រូវបានស្នើសុំចុះបញ្ជីជា គ.ព.គ.ល.គ. ត្រូវតែជា គ.ល.គ. ដែលមានស្រាប់។

៣- គម្រោងដែលត្រូវបានស្នើសុំចុះបញ្ជីជា គ.ព.គ.ល.គ. មិនរាប់បញ្ចូលការទិញ ការលក់ ឬការរួមបញ្ចូលគ្នានៃ គ.ល.គ. ផ្សេងទៀត ដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលរួចហើយ។

៤- គម្រោងដែលត្រូវបានស្នើសុំចុះបញ្ជីជា គ.ព.គ.ល.គ. មិនត្រូវជាការបំពេញបន្ថែមបង្គ្រប់ទុនវិនិយោគនៃ គ.ល.គ. ដែលបានចុះបញ្ជីដំបូង។

៥- គម្រោងដែលត្រូវបានស្នើសុំចុះបញ្ជីជា គ.ព.គ.ល.គ. ត្រូវមានទុនពង្រីកយ៉ាងតិចស្មើទុនអប្បបរមាដូចមានចែងក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

បុគ្គលដែលមានបំណងអនុវត្ត គ.ព.គ.ល.គ. ត្រូវដាក់សំណើសុំចុះបញ្ជីគម្រោងវិនិយោគជា គ.ព.គ.ល.គ. ជាលាយលក្ខណ៍អក្សរនៅ ក.អ.ក. ឬ អ.គ.វ.វ.ខ. តាមនីតិវិធីនិងទម្រង់ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៦នៃអនុក្រឹត្យនេះ។

សំណើសុំចុះបញ្ជីគម្រោងវិនិយោគជា គ.ព.គ.ល.គ ខាងលើនេះ អាចធ្វើឡើងផងដែរតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន។

សំណើសុំចុះបញ្ជីជា គ.ព.គ.ល.គ. ដែលបានបំពេញសព្វគ្រប់ហើយ ត្រូវចុះហត្ថលេខាដោយបុគ្គលដែលត្រូវអនុវត្តគម្រោងវិនិយោគ ឬដោយអ្នកតំណាងដែលមានសិទ្ធិ។

ក្នុងករណីសំណើសុំចុះបញ្ជីជា គ.ព.គ.ល.គ. ត្រូវបានចុះហត្ថលេខាដោយអ្នកតំណាងដែលមានសិទ្ធិ អ្នកតំណាងនោះត្រូវប្រគល់នូវឯកសារដែលបញ្ជាក់អំពីសិទ្ធិជាអ្នកតំណាង និងឯកសារគាំទ្រដែលបញ្ជាក់ពីវិសាលភាពនៃសិទ្ធិសម្រេច។

អ្នកដាក់ពាក្យសុំត្រូវបង់កម្រៃសេវាទៅតាមតារាងតម្លៃសេវាសាធារណៈដែលបានកំណត់។

**មាត្រា៦.-**

បុគ្គលដែលមានបំណងស្នើសុំចុះបញ្ជីជា គ.ធ.វ. ត្រូវដាក់សំណើសុំចុះបញ្ជីគម្រោងវិនិយោគជា គ.ធ.វ. ជាលាយលក្ខណ៍អក្សរនៅ ក.អ.ក. ឬ អ.គ.វ.វ.ខ. តាមនីតិវិធីនិងទម្រង់សង្ខេបដែលមានកំណត់ក្នុងឧបសម្ព័ន្ធទី៧នៃអនុក្រឹត្យនេះ ដើម្បីទទួលបានការធានានិងការការពារដោយអនុលោមតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងកិច្ចព្រមព្រៀងឬសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងវិនិយោគដែលកម្ពុជាបានផ្តល់សច្ចាប័ន។ សំណើសុំចុះបញ្ជីគម្រោងវិនិយោគជា គ.ធ.វ. ខាងលើនេះ អាចធ្វើឡើងផងដែរតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន។

សំណើសុំចុះបញ្ជីជា គ.ធ.វ. ដែលបានបំពេញសព្វគ្រប់ហើយ ត្រូវចុះហត្ថលេខាដោយបុគ្គលដែលត្រូវអនុវត្តគម្រោងវិនិយោគ ឬដោយអ្នកតំណាងដែលមានសិទ្ធិ។ ក្នុងករណីសំណើសុំចុះបញ្ជីជា គ.ធ.វ. ត្រូវបានចុះហត្ថលេខាដោយអ្នកតំណាងដែលមានសិទ្ធិ អ្នកតំណាងនោះត្រូវប្រគល់នូវឯកសារដែលបញ្ជាក់អំពីសិទ្ធិជាអ្នកតំណាង និងឯកសារគាំទ្រដែលបញ្ជាក់ពីវិសាលភាពនៃសិទ្ធិសម្រេច។

អ្នកដាក់ពាក្យសុំត្រូវបង់កម្រៃសេវាទៅតាមតារាងតម្លៃសេវាសាធារណៈដែលបានកំណត់។

ក.អ.ក. ឬ អ.គ.វ.ស.ខ. ត្រូវពិនិត្យសំណើសុំដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ដោយថ្លឹងថ្លែងដល់អត្ថប្រយោជន៍នៃគម្រោងចំពោះសេដ្ឋកិច្ចជាតិ និងអំពីភាពចាំបាច់នៃការផ្តល់វិញ្ញាបនបត្រចុះបញ្ជីជូនអ្នកដាក់ពាក្យសុំដោយឆន្ទានុសិទ្ធិ។

ដើម្បីជាមូលដ្ឋានក្នុងការសម្រេច ក.អ.ក. និង អ.គ.វ.ស.ខ. ត្រូវពិនិត្យមើលលក្ខខណ្ឌ ដូចខាងក្រោម៖

១- អ្នកដាក់ពាក្យសុំ ត្រូវតែជាបុគ្គលដែលអនុវត្តគម្រោងវិនិយោគ ឬដោយអ្នកតំណាងដែលមានសិទ្ធិ។

២- គម្រោងដែលត្រូវបានស្នើសុំចុះបញ្ជីជា គ.ធ.វ. ត្រូវមានទីតាំងអនុវត្ត និងមានទីស្នាក់ការចុះបញ្ជីច្បាស់លាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៣- គម្រោងដែលបានស្នើសុំចុះបញ្ជីជា គ.ធ.វ. មិនមែនជាសកម្មភាពវិនិយោគដែលត្រូវបានហាមឃាត់ដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

៤- នីតិបុគ្គលដែលអនុវត្ត គ.ធ.វ. ពុំត្រូវបានកាន់កាប់ឬគ្រប់គ្រងដោយរូបវន្តបុគ្គលដែលពុំមែនជាពលរដ្ឋនៃបណ្តារដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ឬពលរដ្ឋនៃប្រទេសដែលពុំមានកិច្ចព្រមព្រៀង ឬសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងវិនិយោគដែលកម្ពុជាបានផ្តល់សច្ចាប័ន ឬពលរដ្ឋនៃប្រទេសដែលពុំមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា។

៥- គម្រោងដែលបានស្នើសុំចុះបញ្ជីជា គ.ធ.វ. នេះ មិនត្រូវធ្វើឡើងដោយអ្នកតំណាងដែលមានសិទ្ធិដែលបើកផ្លូវឱ្យជនបរទេសដែលត្រូវបានហាមឃាត់ការធ្វើសកម្មភាពណាមួយនៅព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេសបានទទួលឱកាសវិនិយោគដោយស្របច្បាប់ និងទទួលបានអត្ថប្រយោជន៍ផ្សេងៗ ដោយអនុលោមតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៧.-**

ដោយអនុលោមតាមយន្តការច្រកចេញ-ចូលតែមួយ ក្នុងការពិនិត្យសំណើសុំចុះបញ្ជីគម្រោងវិនិយោគដូចមានកំណត់ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក្នុងថេរវេលាមិនលើសពី ២០(ម្ភៃ) ថ្ងៃ នៃថ្ងៃធ្វើការ ក.អ.ក. ឬ អ.គ.វ.ស.ខ. ត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីជូនអ្នកដាក់ពាក្យសុំ ប្រសិនបើគម្រោងវិនិយោគដែលត្រូវបានស្នើសុំបានបំពេញនិងអនុលោមតាមនីតិវិធីនៃការចុះបញ្ជី ដូចមានចែងនៅក្នុងអនុក្រឹត្យនេះ ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ វិញ្ញាបនបត្រចុះបញ្ជី ត្រូវបានផ្តល់ជូនតាមទម្រង់ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៨ នៃអនុក្រឹត្យនេះ ដោយភ្ជាប់ជាមួយនូវលក្ខខណ្ឌសំខាន់ៗ និងការលើកទឹកចិត្តតាមទម្រង់ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៩ នៃអនុក្រឹត្យនេះ។

វិញ្ញាបនបត្រចុះបញ្ជី ត្រូវមានភ្ជាប់នូវបារកូដដែលមានលេខសម្គាល់ ឬឃ្យូអរកូដ ឬប្រព័ន្ធបច្ចេកវិទ្យាដទៃទៀតដែលផ្ទុកទិន្នន័យបឋមមួយចំនួនពាក់ព័ន្ធនឹងគម្រោងវិនិយោគដែលត្រូវបានចុះបញ្ជី ដើម្បីជាប្រយោជន៍ដល់ការចុះបញ្ជីពាក់ព័ន្ធនានា និងសម្រាប់ការអនុវត្តគម្រោងវិនិយោគ។ ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត មន្ទីរ និងអង្គភាពដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាក់ព័ន្ធនិងការពិនិត្យអនុលោមភាពនៃការអនុវត្តគម្រោងវិនិយោគ មិនអាចតម្រូវឱ្យអ្នកដាក់ពាក្យសុំឬវិនិយោគិនផ្តល់នូវឯកសារនានាដែលមានស្រាប់នៅក្នុងបារកូដដែលមានលេខសម្គាល់ ឬ

ឃុំអរក្ខ ឬប្រព័ន្ធបច្ចេកវិទ្យាដទៃទៀត ដែលជាប់នៅលើវិញ្ញាបនបត្រចុះបញ្ជី ដែលចេញដោយ ក.អ.ក. ឬ អ.គ.វ.ស.ខ. បានទេ។

អនុលោមទៅតាមលក្ខខណ្ឌជាក់ស្តែង ក.អ.ក. ឬ អ.គ.វ.ស.ខ. មានសិទ្ធិពន្យារពេល ឬបដិសេធការចុះបញ្ជី ដល់អ្នកដាក់ពាក្យសុំ ចំពោះគ្រប់សំណើសុំចុះបញ្ជីគម្រោងវិនិយោគ ដោយមានការជូនដំណឹងដល់អ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់អំពីមូលហេតុច្បាស់លាស់ ក្រោមហេតុផលណាមួយដូចខាងក្រោម៖

១- សំណើសុំចុះបញ្ជីគម្រោងវិនិយោគមិនអនុលោមតាមនីតិវិធីនៃការចុះបញ្ជី ដូចមានចែងក្នុងអនុក្រឹត្យនេះ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ឬ

២- អ្នកដាក់ពាក្យសុំមិនបានផ្តល់ជូននូវព័ត៌មានគ្រប់គ្រាន់ ដែលតម្រូវដោយច្បាប់ឬអនុក្រឹត្យនេះ។ ឬ

៣- គម្រោងដែលបានស្នើសុំមានវេទយិតភាពខ្ពស់ ដែលតម្រូវឱ្យមានការសុំយោបល់សម្រេចជាមុនពីកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ឬរាជរដ្ឋាភិបាល។

ការជូនដំណឹងអំពីការពន្យារពេលការចុះបញ្ជីដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រានេះ ត្រូវបញ្ជាក់ឱ្យបានច្បាស់នូវចំណុចឬអំពីលក្ខខណ្ឌ និងអំពីថេរវេលាសម្រាប់អ្នកដាក់ពាក្យសុំត្រូវកែតម្រូវឬបំពេញ។

**មាត្រា៨.-**

ការចេញវិញ្ញាបនបត្រចុះបញ្ជីជូនអ្នកដាក់ពាក្យសុំ មិនមែនជាការលើកលែងឱ្យគម្រោងវិនិយោគរួចផុតពីការទទួលនូវការយល់ព្រមការអនុញ្ញាត អាជ្ញាបណ្ណ លិខិតអនុញ្ញាត ឬបញ្ជិកានានា ដែលតម្រូវដោយក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត មន្ទីរ និងអង្គភាព ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ទោះបីជាផុតរយៈពេល ២០ (ម្ភៃ) ថ្ងៃ នៃថ្ងៃធ្វើការ ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៧ នៃអនុក្រឹត្យនេះក៏ដោយ ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត មន្ទីរ និងអង្គភាពមានសមត្ថកិច្ចត្រូវតែផ្តល់ការយល់ព្រមការអនុញ្ញាត អាជ្ញាបណ្ណ តាមការកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ការយឺតយ៉ាវក្នុងការចេញលិខិតអនុញ្ញាតនានាពីក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត មន្ទីរ និងអង្គភាពមានសមត្ថកិច្ចដោយគ្មានមូលហេតុសមរម្យ មិនត្រូវជាកម្មវត្ថុនៃការរាំងស្ទះដល់ដំណើរការអនុវត្តគម្រោងវិនិយោគនោះឡើយ។ កាលបរិច្ឆេទនៃការចេញវិញ្ញាបនបត្រចុះបញ្ជីជូនអ្នកដាក់ពាក្យសុំ គឺជាកាលបរិច្ឆេទនៃការចាប់ផ្តើមអនុវត្តគម្រោង។

**មាត្រា៩.-**

ក្រោយពេលពិនិត្យឃើញថាសំណុំពាក្យសុំចុះបញ្ជីគម្រោងវិនិយោគ បានអនុលោមទៅតាមនីតិវិធីជាធរមានរួចហើយ មន្ត្រីទទួលបន្ទុកត្រូវចាត់ចែងសំណុំពាក្យសុំនេះទៅតាមនីតិវិធីរដ្ឋបាលផ្ទៃក្នុងរបស់ ក.អ.ក. ឬ អ.គ.វ.ស.ខ. ដោយគ្មានការពន្យារពេលឡើយ។

នៅពេលទទួលសំណុំពាក្យសុំចុះបញ្ជីគម្រោងវិនិយោគ មន្ត្រីទទួលបន្ទុកត្រូវចេញលិខិតបញ្ជាក់ការទទួលសំណុំពាក្យសុំនេះជូនអ្នកដាក់ពាក្យសុំ សម្រាប់ការមកទទួលយកវិញ្ញាបនបត្រចុះបញ្ជីនៅពេលក្រោយ។

ក.អ.ក. ឬ អ.គ.វ.ស.ខ. ត្រូវចាត់ចែងការពិនិត្យនិងការសម្រេចលើសំណើសុំចុះបញ្ជីគម្រោងវិនិយោគ តាមរយៈយន្តការច្រកចេញ-ចូលតែមួយដែលបានកំណត់ដោយច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។ មន្ត្រីតំណាងក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត មន្ទីរ និងអង្គភាពដែលប្រចាំការនៅ ក.អ.ក. ឬ អ.គ.វ.ស.ខ. ត្រូវផ្តល់មតិឯកភាព ឬបដិសេធជាលាយលក្ខណ៍អក្សរលើសំណុំពាក្យសុំចុះបញ្ជីនេះ ដោយគ្មានការយឺតយ៉ាវទៅតាមយន្តការច្រក

ចេញ-ចូលតែមួយ។ មតិឯកភាពឬបដិសេធនេះ ត្រូវចាត់ទុកថាជាមតិរបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត មន្ទីរ និងអង្គភាពសាមី។ បែបបទនិងរបៀបរបបការងារនៃយន្តការច្រកចេញ-ចូលតែមួយ ត្រូវកំណត់ដោយ **ក.អ.ក.** ឬ **អ.គ.វ.វ.ខ.**។

**ក.អ.ក.** ឬ **អ.គ.វ.វ.ខ.** ត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីជូនអ្នកដាក់ពាក្យសុំ បន្ទាប់ពីទទួលបានការសម្រេចដោយយន្តការច្រកចេញ-ចូលតែមួយ។ វិញ្ញាបនបត្រចុះបញ្ជីនេះអាចចេញដោយលិខិតជាលាយលក្ខណ៍អក្សរ តាមរយៈការប្រគល់ជូនអ្នកដាក់ពាក្យសុំដោយផ្ទាល់ដៃ ឬតាមប្រៃសណីយ៍កម្ពុជា ឬតាមទម្រង់អេឡិចត្រូនិក ឬតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដែលប្រើប្រាស់ជាផ្លូវការដោយ **ក.អ.ក.** ឬ **អ.គ.វ.វ.ខ.**។

**មាត្រា១០._**

**ក.អ.ក.** ឬ **អ.គ.វ.វ.ខ.** មានកាតព្វកិច្ចចុះពិនិត្យការអនុវត្តគម្រោងវិនិយោគ ដោយអនុលោមតាមមាត្រា១៣ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យអនុលោមភាពគតិយុត្ត និងការអនុវត្តកាតព្វកិច្ចនានា ដែលជាលក្ខខណ្ឌនៃការទទួលបានវិញ្ញាបនបត្រចុះបញ្ជី។

ការចុះពិនិត្យការអនុវត្តគម្រោងវិនិយោគជាក់ស្តែង ត្រូវធ្វើឡើងជាទៀងទាត់ឬតាមការចាំបាច់ ដោយមានការជូនដំណឹងជាមុនទៅបុគ្គលពាក់ព័ន្ធនឹងការអនុវត្តគម្រោងវិនិយោគ លើកលែងតែក្នុងករណីសង្ស័យ ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត មន្ទីរ និងអង្គភាពពាក់ព័ន្ធអាចចុះត្រួតពិនិត្យដោយមិនចាំបាច់ជូនដំណឹងជាមុន។

ការចុះពិនិត្យការអនុវត្តគម្រោងវិនិយោគជាក់ស្តែងខាងលើនេះ មានគោលបំណង៖

១- ពិនិត្យតម្រូវការនិងការប្រើប្រាស់សម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និង/ឬធាតុចូលផលិតកម្ម សម្រាប់ការអនុវត្តគម្រោងវិនិយោគ ស្របតាមគោលការណ៍កំណត់។ ចំពោះធាតុចូលផលិតកម្មដែលនាំចូលដោយទទួលបានការលើកទឹកចិត្តពន្ធអាករ មិនអនុញ្ញាតឱ្យស្តុកទុកហួសរយៈពេលកំណត់នៃការប្រើប្រាស់ទំនិញ ឬស្តុកទុកមិនប្រើប្រាស់អស់រយៈពេលយូរដោយគ្មានមូលហេតុច្បាស់លាស់ ហើយមិនបានស្នើសុំការអនុញ្ញាតនាំចេញទៅវិញ ឬបញ្ចេញលក់លើទីផ្សារក្នុងស្រុក ឬផ្ទេរទៅឱ្យគម្រោងវិនិយោគផ្សេងស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

២- ពិនិត្យវឌ្ឍនភាពនៃការអនុវត្តគម្រោងវិនិយោគ រួមទាំងគម្រោងវិនិយោគដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរដ្ឋ និង/ឬហិរញ្ញវត្ថុសាធារណៈ និងការប្រើប្រាស់កញ្ចប់លើកទឹកចិត្តវិនិយោគដែល **ក.អ.ក.** ឬ **អ.គ.វ.វ.ខ.** បានផ្តល់ឱ្យគម្រោងវិនិយោគ។

៣- ពិនិត្យអត្ថិភាពនិងនត្ថិភាពជាក់ស្តែងនៃគម្រោងវិនិយោគ។

**មាត្រា១១._**

វិនិយោគិនមានកាតព្វកិច្ចផ្តល់របាយការណ៍ក្នុងរយៈពេលនិងតាមទម្រង់ដែលត្រូវបានកំណត់ដូចខាងក្រោម៖

១- ក្នុងរយៈពេល ២០(ម្ភៃ)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទបិទបញ្ចប់ការប្រកាសពន្ធ វិនិយោគិនមានកាតព្វកិច្ចផ្តល់ជូន **ក.អ.ក.** ឬ **អ.គ.វ.វ.ខ.** នូវរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ ស្តីពី៖

ក- ការនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និង/ឬធាតុចូលផលិតកម្មសម្រាប់បម្រើខ្សែច្រវាក់ផលិតកម្មរបស់ខ្លួន។

ខ- ការអនុវត្តគម្រោងវិនិយោគជាក់ស្តែង ដោយបញ្ជាក់ពីទុនវិនិយោគ ចំនួនបុគ្គលិក-កម្មករ ស្ថានភាពផលិតកម្ម ស្ថានភាពទីផ្សារ និងការអនុវត្តកាតព្វកិច្ចពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន សង្គម។

គ- ការបំពេញកាតព្វកិច្ចសារពើពន្ធត្រឹមត្រូវតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

២- ទម្រង់និងបែបបទលម្អិតនៃគំរូរបាយការណ៍ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ **ក.អ.ក.** ឬ **អ.គ.វ. វ.ខ.**។

៣- កាតព្វកិច្ចនៃការផ្តល់របាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ៖

ក- ផ្អែកលើមូលដ្ឋានរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ ដែលផ្តល់ដោយវិនិយោគិន **ក.អ.ក.** ឬ **អ.គ.វ.វ.ខ.** ត្រូវចេញនៅឆ្នាំបន្ទាប់នូវវិញ្ញាបនបត្របញ្ជាក់ពីការបំពេញកាតព្វកិច្ចរបស់វិនិយោគិន។

ខ- ក្នុងករណី **ក.អ.ក.** ឬ **អ.គ.វ.វ.ខ.** ខកខានមិនបានចេញវិញ្ញាបនបត្របញ្ជាក់ពីការបំពេញកាតព្វកិច្ចរបស់វិនិយោគិន ខណៈវិនិយោគិនបានផ្តល់របាយការណ៍ត្រឹមត្រូវតាមការកំណត់នៃមាត្រានេះ ការខកខាននេះ ត្រូវបានចាត់ទុកថាវិនិយោគិនបានទទួលវិញ្ញាបនបត្របញ្ជាក់ពីការបំពេញកាតព្វកិច្ចរបស់ខ្លួនដោយស្វ័យប្រវត្តិ។

គ- ក្នុងករណីវិនិយោគិនខកខានមិនបានផ្តល់របាយការណ៍ត្រឹមត្រូវតាមការកំណត់នៃមាត្រានេះទេ គម្រោងវិនិយោគ នឹងត្រូវបាត់បង់ការលើកទឹកចិត្ត និងការធានានិងការការពារនានាដែលធ្លាប់ទទួលបានកន្លងមក។ វិនិយោគិនត្រូវលើកសំណើមក **ក.អ.ក.** ឬ **អ.គ.វ.វ.ខ.** សុំការចេញវិញ្ញាបនបត្របញ្ជាក់ពីការបំពេញកាតព្វកិច្ចរបស់ខ្លួន ដោយភ្ជាប់មកជាមួយនូវរបាយការណ៍និងលិខិតបញ្ជាក់ពីមូលហេតុនៃការខកខានមិនបានផ្តល់របាយការណ៍ មុននឹងគម្រោងវិនិយោគត្រូវទទួលបានការលើកទឹកចិត្ត និងការធានានិងការការពារនានាកន្លងមកឡើងវិញ។

**មាត្រា១២._**

វិនិយោគិន ត្រូវដាក់សំណើសុំការសម្រេចជាលាយលក្ខណ៍អក្សរមក **ក.អ.ក.** ឬ **អ.គ.វ.វ.ខ.** ដើម្បីទទួលបាននូវការយល់ព្រមលើការផ្លាស់ប្តូរនានាដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគ និងមាននៅក្នុងលក្ខន្តិកៈរបស់វិនិយោគិន ដែលបានតម្កល់ទុកនៅ **ក.អ.ក.** ឬ **អ.គ.វ.វ.ខ.**។ **ក.អ.ក.** ឬ **អ.គ.វ.វ.ខ.** ត្រូវធ្វើការពិនិត្យនិងសម្រេចលើសំណើសុំនេះ ទៅតាមនីតិវិធីជាធរមាន។

## ជំពូកទី៣

## ការលើកទឹកចិត្តវិនិយោគ

**មាត្រា១៣._**

លើកលែងតែមានកំណត់ផ្សេងដោយច្បាប់ សកម្មភាពវិនិយោគទាំងឡាយណាដែលមិនស្ថិតនៅក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ អាចទទួលបានការលើកទឹកចិត្តជាមូលដ្ឋាន ទៅតាមលក្ខណៈវិនិច្ឆ័យដែលកំណត់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ក្រោយពីទទួលបានវិញ្ញាបនបត្រចុះបញ្ជីបញ្ជាក់ឋានៈជា គ.ល.គ. ដូចមានចែងក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

ការពិនិត្យសម្រេច ឬកំណត់ថាសកម្មភាពវិនិយោគដែលមិនស្ថិតក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ ត្រូវផ្អែកលើសំណុំពាក្យសុំចុះបញ្ជីគម្រោងវិនិយោគនិងការបញ្ជាក់ផ្សេងៗជាផ្លូវការ។

ដើម្បីទទួលបានការលើកទឹកចិត្តជាមូលដ្ឋានផ្នែកពន្ធដារ គ.ល.ត. ត្រូវបំពេញកាតព្វកិច្ចទុនវិនិយោគ និង/ឬ ទំហំដី និង/ ឬលក្ខខណ្ឌផ្សេងទៀត ឱ្យបានតាមការកំណត់ក្នុងអនុក្រឹត្យនេះ ក្នុងរយៈពេលណាមួយឆាប់ជាងគេ រវាងរយៈពេលដូចមានកំណត់តាមផែនការវិនិយោគរបស់ គ.ល.ត. នៅពេលដាក់ពាក្យស្នើសុំ និងឆ្នាំដែល គ.ល.ត. ទទួលប្រាក់ចំណូលដំបូង។ ដោយឡែក គ.ល.ត. ក្នុងវិស័យកសិកម្ម អាចបំពេញកាតព្វកិច្ចទុនវិនិយោគ និង/ឬទំហំដី និង/ឬលក្ខខណ្ឌផ្សេងទៀត ឱ្យបានតាមការកំណត់នៃអនុក្រឹត្យនេះ រហូតដល់ឆ្នាំចុងក្រោយនៃរយៈពេលលើកលែងពន្ធ។

សកម្មភាពឬគម្រោងវិនិយោគដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរដ្ឋនិង/ ឬហិរញ្ញវត្ថុសាធារណៈ ដែលពុំមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំទទួលបានការចុះបញ្ជីគម្រោងវិនិយោគ និងមិនទទួលបានការលើកទឹកចិត្តទេ។

**មាត្រា១៤.-**

សកម្មភាពវិនិយោគដែលបានចុះបញ្ជីជា គ.ល.ត. ដោយអនុលោមតាមមាត្រា ២៦ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិជ្រើសរើសការលើកទឹកចិត្តជាមូលដ្ឋាន តាមជម្រើសណាមួយ ដូចខាងក្រោម៖

១- ជម្រើសទី១ ត្រូវទទួលបានការលើកទឹកចិត្ត ដូចខាងក្រោម៖

ក- ទទួលបានការលើកលែងពន្ធលើប្រាក់ចំណូល គិតចាប់ពីពេលដែលទទួលបានប្រាក់ចំណូលលើកដំបូងពីសកម្មភាពអាជីវកម្ម ក្នុងរយៈពេលជាក់លាក់ណាមួយ ទៅតាមប្រភេទក្រុមសកម្មភាពវិនិយោគដែលបានចែងក្នុងបញ្ជីសកម្មភាពវិនិយោគនៃឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ ដូចខាងក្រោម៖

- ៩ (ប្រាំបួន)ឆ្នាំ សម្រាប់ក្រុម ១
- ៦ (ប្រាំមួយ)ឆ្នាំ សម្រាប់ក្រុម ២
- ៣ (បី)ឆ្នាំ សម្រាប់ក្រុម ៣។

ខ- មានសិទ្ធិទទួលបានការលើកទឹកចិត្តឱ្យបង់ពន្ធលើប្រាក់ចំណូលតាមអត្រាកំណើនតាមពេលធៀបទៅនឹងទឹកប្រាក់ពន្ធត្រូវបង់សរុប បន្ទាប់ពីផុតរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ដូចខាងក្រោម៖

- ២៥ (ម្ភៃប្រាំ)ភាគរយ សម្រាប់២ (ពីរ)ឆ្នាំដំបូង
- ៥០ (ហាសិប)ភាគរយ សម្រាប់២ (ពីរ)ឆ្នាំបន្ទាប់ និង
- ៧៥ (ចិតសិបប្រាំ)ភាគរយ សម្រាប់២ (ពីរ)ឆ្នាំចុងក្រោយ។

គ- ទទួលបានការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូលក្នុងរយៈពេលជាក់លាក់ណាមួយ ទៅតាមប្រភេទក្រុមសកម្មភាពវិនិយោគ ដែលបានចែងក្នុងបញ្ជីសកម្មភាពវិនិយោគនៃឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ ដូចខាងក្រោម៖

- ៩ (ប្រាំបួន)ឆ្នាំ សម្រាប់ក្រុម ១
- ៦ (ប្រាំមួយ)ឆ្នាំ សម្រាប់ក្រុម ២
- ៣ (បី)ឆ្នាំ សម្រាប់ក្រុម ៣។

ឃ- ទទួលបានការលើកលែងពន្ធអប្បបរមា ដោយត្រូវមានរបាយការណ៍សវនកម្មឯករាជ្យ។

ង- ទទួលបានការលើកលែងអាករនាំចេញ លើកលែងតែមានចែងដោយឡែកនៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

២- ជម្រើសទី២ ត្រូវទទួលបានការលើកទឹកចិត្ត ដូចខាងក្រោម៖

ក- មានសិទ្ធិកាត់កងចំណាយមូលធនតាមរយៈរំលស់ពិសេស ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

ខ- មានសិទ្ធិកាត់កងក្នុងអត្រា ២០០(ពីររយ)ភាគរយ លើចំណាយជាក់លាក់ផ្សេងទៀត ក្នុងរយៈពេលជាក់លាក់ណាមួយ ទៅតាមប្រភេទក្រុមសកម្មភាពវិនិយោគដែលបានចែងក្នុងបញ្ជីសកម្មភាពវិនិយោគនៃឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ ដូចខាងក្រោម៖

- ៩ (ប្រាំបួន)ឆ្នាំ សម្រាប់ក្រុម ១
- ៦ (ប្រាំមួយ)ឆ្នាំ សម្រាប់ក្រុម ២
- ៣ (បី)ឆ្នាំ សម្រាប់ក្រុម ៣។

- ចំណាយជាក់លាក់ រួមមាន៖
  - ចំណាយលើការបណ្តុះបណ្តាលជំនាញជាក់លាក់ដល់និយោជិតខ្មែរ ដើម្បីជំនួសនិយោជិតបរទេស
  - ចំណាយលើការប្រើប្រាស់បញ្ជីគណនេយ្យតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
  - ចំណាយលើការផ្តល់អាហារូបករណ៍ជូននិយោជិតខ្មែរទៅសិក្សាជំនាញជាក់លាក់ណាមួយនៅបរទេស
  - ចំណាយលើការសិក្សា ស្រាវជ្រាវនិងអភិវឌ្ឍន៍ និងការជួលអ្នកជំនាញបរទេសមកបណ្តុះបណ្តាលលើបច្ចេកវិទ្យាថ្មីៗ បដិវត្តន៍ឧស្សាហកម្មទី៤ មានជាអាទិ៍ បញ្ញាសិប្បនិម្មិត និងបច្ចេកវិទ្យារ៉ូបូត ឬការរៀបចំដំឡើងស្តុកទុកទិន្នន័យធំ។

គ- ទទួលបានការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូលក្នុងរយៈពេលជាក់លាក់ណាមួយ ទៅតាមប្រភេទក្រុមសកម្មភាពវិនិយោគ ដែលបានចែងក្នុងបញ្ជីសកម្មភាពវិនិយោគនៃឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ ដូចខាងក្រោម៖

- ៩ (ប្រាំបួន)ឆ្នាំ សម្រាប់ក្រុម ១
- ៦ (ប្រាំមួយ)ឆ្នាំ សម្រាប់ក្រុម ២
- ៣ (បី)ឆ្នាំ សម្រាប់ក្រុម ៣។

ឃ-ទទួលបានការលើកលែងពន្ធអប្បបរមា ដោយត្រូវមានរបាយការណ៍សវនកម្មឯករាជ្យ។

ង- ទទួលបានការលើកលែងអាករនាំចេញ លើកលែងតែមានចែងដោយឡែកនៅក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

ក្រៅពីការលើកទឹកចិត្តតាមរយៈជម្រើសទាំង ២ (ពីរ) ខាងលើ៖

១- គ.ល.គ. មានសិទ្ធិនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋ នូវសម្ភារៈសាងសង់ បរិក្ខារសំណង់ និងសម្ភារៈបរិក្ខារផលិតកម្មសម្រាប់បម្រើខ្សែច្រវាក់ផលិតកម្មរបស់ខ្លួន។

២- បន្ថែមលើចំណុច១នៃកថាខណ្ឌនេះ គ.ល.គ. បម្រើឱ្យការនាំចេញ ឬ គ.ល.គ. ដែលជាប្រភេទឧស្សាហកម្មគាំទ្រដល់ គ.ល.គ. បម្រើឱ្យការនាំចេញ មានសិទ្ធិនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋ នូវធាតុចូលផលិតកម្មសម្រាប់បម្រើខ្សែច្រវាក់ផលិតកម្មរបស់ខ្លួន។ ក្នុងករណីធាតុចូលផលិតកម្ម ពុំបាន

ប្រើប្រាស់សម្រាប់ផ្គត់ផ្គង់ឱ្យខ្សែច្រវាក់ផលិតកម្ម គ.ល.ត. បម្រើឱ្យការនាំចេញ ឬ គ.ល.ត. ដែលជាប្រភេទឧស្សាហកម្មគាំទ្រដល់ គ.ល.ត. បម្រើឱ្យការនាំចេញ ត្រូវបង់ពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម តាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៣- លើកលែងតែមានកំណត់ផ្សេងដោយច្បាប់ សកម្មភាពវិនិយោគទាំងឡាយណាដែលស្ថិតនៅក្នុងឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ ត្រូវទទួលបានការលើកទឹកចិត្តលើការនាំចូល ដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ និងសម្ភារៈបរិក្ខារផលិតកម្មសម្រាប់បម្រើខ្សែច្រវាក់ផលិតកម្មរបស់ខ្លួន តែមិនទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ ក្រោយពីទទួលបានវិញ្ញាបនបត្រចុះបញ្ជីបញ្ជាក់ឋានៈជា គ.ល.ត. ដូចមានចែងក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

៤- គ.ល.ត. បម្រើទីផ្សារក្នុងស្រុក ដែលមានសកម្មភាពវិនិយោគស្ថិតក្នុងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះ មានសិទ្ធិនាំចូល ដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋ នូវធាតុចូលផលិតកម្មសម្រាប់បម្រើខ្សែច្រវាក់ផលិតកម្មរបស់ខ្លួន។

៥- ចំពោះ គ.ល.ត. បម្រើទីផ្សារក្នុងស្រុក ដែលមានលទ្ធភាពនាំចេញដោយផ្ទាល់ ឬផ្គត់ផ្គង់ជាធាតុចូលផលិតកម្មដល់ គ.ល.ត. បម្រើឱ្យការនាំចេញនូវផ្នែកណាមួយនៃផលិតផលដែលបានផលិតពីធាតុចូលផលិតកម្មដែលបាននាំចូលនិងបំពេញកាតព្វកិច្ចពន្ធអាកររួចហើយ ត្រូវទទួលបានការបង្វិលសង ឬទុកសម្រាប់ការទូទាត់នូវពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ចំពោះទំនិញដែលត្រូវបាននាំចូលនៅពេលបន្ទាប់ ដោយអនុលោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីជាធរមាន តាមការស្នើសុំរបស់វិនិយោគិន។

**មាត្រា១៥.-**

ក្រៅពីការលើកទឹកចិត្តជាមូលដ្ឋាន ដែលមានចែងក្នុងមាត្រា១៤ នៃអនុក្រឹត្យនេះ គ.ល.ត. ទទួលបានការលើកទឹកចិត្តបន្ថែម ដូចខាងក្រោម៖

១- គ.ល.ត. ទទួលបានការលើកលែងអាករលើតម្លៃបន្ថែម ចំពោះការទិញធាតុចូលផលិតកម្មដែលផលិតក្នុងស្រុកសម្រាប់បម្រើដល់ការអនុវត្ត គ.ល.ត.។ ការលើកលែងអាករលើតម្លៃបន្ថែមនេះ ត្រូវអនុវត្តតាមអត្រា ០ (សូន្យ) ភាគរយ។

២- គ.ល.ត. ទទួលបានការកាត់កងចំណាយក្នុងអត្រា ១៥០ (មួយរយហាសិប)ភាគរយ ពីមូលដ្ឋានគិតពន្ធចំពោះសកម្មភាពណាមួយដូចខាងក្រោម៖

ក- ការស្រាវជ្រាវ អភិវឌ្ឍន៍ និងនវានុវត្តន៍។

ខ- ការអភិវឌ្ឍធនធានមនុស្សតាមរយៈការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈនិងជំនាញដល់កម្មករនិយោជិតខ្មែរ។

គ- ការសាងសង់កន្លែងស្នាក់នៅ កន្លែងបរិភោគអាហារ អាហារដ្ឋានដោយឥតគិតថ្លៃ ឬអាហារដ្ឋានដែលមានតម្លៃសមរម្យ ទារកដ្ឋាន និងសុខុបត្ថម្ភវត្ថុផ្សេងទៀតសម្រាប់កម្មករនិយោជិត។

ឃ- ការធ្វើទំនើបកម្មលើគ្រឿងម៉ាស៊ីនដើម្បីបម្រើឱ្យខ្សែច្រវាក់ផលិតកម្ម។

ង- ការផ្តល់ការលើកកម្ពស់សុខុមាលភាពដល់កម្មករនិយោជិតខ្មែរ ដូចជាការផ្តល់មធ្យោបាយដឹកជញ្ជូនប្រកបដោយផាសុកភាពដល់កម្មករនិយោជិត ក្នុងការធ្វើដំណើរទៅមកពីកន្លែងស្នាក់នៅទៅរោងចក្រ

កន្លែងស្នាក់នៅ កន្លែងបរិភោគអាហារ អាហារដ្ឋានដោយឥតគិតថ្លៃ ឬអាហារដ្ឋានដែលមានតម្លៃសមរម្យ ទារកដ្ឋាន និងសុខូបត្ថម្ភវត្ថុដទៃទៀត។

ច- ការវិនិយោគឬសាងសង់ហេដ្ឋារចនាសម្ព័ន្ធប្រព្រឹត្តកម្មសំណល់គ្រប់ប្រភេទ ជាអាទិ៍ សំណល់រឹង សំណល់គ្រោះថ្នាក់ សំណល់រាវ ផ្សេង។

៣- គ.ល.គ. មានសិទ្ធិនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋ នូវសម្ភារៈសាងសង់ និងបរិក្ខារសំណង់ សម្រាប់សាងសង់កន្លែងស្នាក់នៅ ទារកដ្ឋាន បន្ទប់សង្គ្រោះបឋម កន្លែងបរិភោគអាហារ អាហារដ្ឋានដោយឥតគិតថ្លៃ ឬអាហារដ្ឋានដែលមានតម្លៃសមរម្យ សម្រាប់តែកម្មករនិយោជិតនៃគម្រោងវិនិយោគរបស់ខ្លួន ដែលស្ថិតនៅក្នុងទីតាំងនៃគម្រោងវិនិយោគ។

**មាត្រា១៦.-**

ការផ្ដល់ការលើកទឹកចិត្តដល់ គ.ព.គ.ល.គ. ត្រូវអនុវត្តតាមខ្លឹមសារដូចខាងក្រោម៖

១- គ.ល.គ. ដែលស្នើសុំពង្រីកសកម្មភាពវិនិយោគរបស់ខ្លួន ត្រូវបានទទួលការលើកទឹកចិត្តនូវរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ក្នុងករណីដែលការពង្រីកគម្រោងនោះធ្វើឡើងតាមរូបភាពណាមួយ ដូចខាងក្រោម៖

ក- ការពង្រីកផលិតកម្មដែលមានស្រាប់។

ខ- ការពង្រីកតាមរយៈការធ្វើពិពិធកម្មមុខសញ្ញាផលិតកម្មដែលស្ថិតក្នុងខ្សែស្រឡាយផលិតផលជាមួយគ្នា។

គ- ការពង្រីកតាមរយៈការបំពាក់បច្ចេកវិទ្យាទំនើបថ្មីដែលលើកកម្ពស់ផលិតភាពឬការពារបរិស្ថាន។

ករណីការពង្រីកសកម្មភាពក្រោមរូបភាពផ្សេងទៀត ត្រូវមានការអនុញ្ញាតពីរាជរដ្ឋាភិបាល។

២- ដោយរាប់ចាប់ពីពេលពង្រីកនៃ គ.ល.គ. គ.ព.គ.ល.គ. ត្រូវទទួលបានការលើកលែងពន្ធលើប្រាក់ចំណូលទៅតាមសកម្មភាពវិនិយោគនៃគម្រោងដើម ក្នុងរយៈពេលជាក់លាក់ណាមួយ ទៅតាមប្រភេទក្រុមសកម្មភាពវិនិយោគដែលបានចែងក្នុងបញ្ជីសកម្មភាពវិនិយោគនៃឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ ដូចខាងក្រោម៖

ក- ៩ (ប្រាំបួន)ឆ្នាំ សម្រាប់ក្រុម ១

ខ- ៦ (ប្រាំមួយ)ឆ្នាំ សម្រាប់ក្រុម ២

គ- ៣ (បី)ឆ្នាំ សម្រាប់ក្រុម ៣។

៣- ចំណែកនៃប្រាក់ចំណូលដែលត្រូវលើកលែងពន្ធសម្រាប់ គ.ព.គ.ល.គ ស្មើនឹងប្រាក់ចំណូលជាប់ពន្ធសរុបគុណនឹងអត្រាទុនពង្រីកនៃ គ.ល.គ.។ អត្រាទុនពង្រីកនៃ គ.ល.គ. ស្មើនឹងទុនពង្រីកនៃ គ.ល.គ. ចែកនឹងទុនវិនិយោគសរុប។ ទុនវិនិយោគសរុប ស្មើនឹងទុនវិនិយោគនៃ គ.ល.គ. ដែលបានចុះបញ្ជីដំបូង បូកនឹងទុនពង្រីកនៃ គ.ល.គ. ដែលត្រូវទទួលបានការលើកទឹកចិត្ត។ រូបមន្តនៃការគណនា ដូចខាងក្រោម៖

| | | |
|---|---|---|
| បចល. | = | បចស. x (ទព. / ទស.) |
| បចល. | = | ប្រាក់ចំណូលដែលត្រូវទទួលការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូល |
| បចស. | = | ប្រាក់ចំណូលជាប់ពន្ធសរុប |
| ទព. | = | ទុនពង្រីក គ.ល.គ ដែលត្រូវទទួលបានការលើកទឹកចិត្ត |
| ទស. | = | ទុនវិនិយោគសរុប (ទច. + ទព.) |
| ទច. | = | ទុនវិនិយោគនៃ គ.ល.គ. ដែលបានចុះបញ្ជីដំបូង |

៤- ប្រាក់រំដោះពន្ធលើប្រាក់ចំណូលសម្រាប់ គ.ព.គ.ល.គ. ត្រូវបានលើកលែងផ្អែកតាមសមាមាត្រនៃអត្រាទុនពង្រីក គ.ល.គ. ក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូលលើគម្រោងពង្រីក។

៥- គ.ព.គ.ល.គ. ទទួលបានការលើកលែងពន្ធអប្បបរមា ដោយត្រូវមានរបាយការណ៍សវនកម្មឯករាជ្យ។

**មាត្រា១៧._**

គ.ល.គ. ផ្គុំដំឡើងរថយន្តថ្មី មានសិទ្ធិទទួលបាននូវការលើកទឹកចិត្តក្រោមរូបភាពនៃការបញ្ចុះអត្រាពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម សម្រាប់ការនាំចូលគ្រឿងបង្គុំដំឡើងរថយន្តបម្រើទីផ្សារក្នុងស្រុក តាមលក្ខណៈវិនិច្ឆ័យ និងអត្រាបញ្ចុះពន្ធដូចខាងក្រោម៖

- ទទួលបានការលើកទឹកចិត្តបញ្ចុះអត្រាពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ចំនួន៥០ (ហាសិប)ភាគរយ ចំពោះ គ.ល.គ. ដែលប្រើប្រាស់គ្រឿងបង្គុំជាផលិតផលសម្រេចដែលមិនតម្រូវឱ្យមានដំណើការកែច្នៃបន្ថែមទៀត មានធាតុផ្សំក្នុងស្រុកយ៉ាងតិច៣ (បី) ភាគរយ ហើយបំពេញបានលក្ខខណ្ឌ២(ពីរ) ក្នុងចំណោមលក្ខខណ្ឌ៣(បី)ខាងក្រោម(១) ប្រើប្រាស់គ្រឿងបង្គុំចាប់ពី៤០០ (បួនរយ) បំណែកឡើងទៅក្នុងរថយន្តមួយគ្រឿង(២) មានទុនវិនិយោគចាប់ពី ៥.០០០.០០០(ប្រាំលាន) ដុល្លារអាម៉េរិកឡើងទៅ (៣) ប្រើប្រាស់កម្លាំងពលកម្មចាប់ពី១៥០(មួយរយហាសិប) នាក់ឡើង
- ទទួលបានការលើកទឹកចិត្តបញ្ចុះអត្រាពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ចំនួន៧០ (ចិតសិប) ភាគរយ ចំពោះ គ.ល.គ. ដែលប្រើប្រាស់គ្រឿងបង្គុំជាផលិតផលសម្រេចមិនទាន់បាញ់ថ្នាំ មានធាតុផ្សំក្នុងស្រុកយ៉ាងតិច៥ (ប្រាំ) ភាគរយ ហើយបំពេញបានលក្ខខណ្ឌ២ (ពីរ) ក្នុងចំណោមលក្ខខណ្ឌ៣(បី) ខាងក្រោម(១) ប្រើប្រាស់គ្រឿងបង្គុំចាប់ពី៥០០(ប្រាំរយ) បំណែកឡើងទៅក្នុងរថយន្តមួយគ្រឿង (២) មានទុនវិនិយោគចាប់ពី ១៥.០០០.០០០ (ដប់ប្រាំលាន) ដុល្លារអាម៉េរិកឡើងទៅ(៣) ប្រើប្រាស់កម្លាំងពលកម្មចាប់ពី៣០០(បីរយ) នាក់ឡើងទៅ
- ទទួលបានការលើកទឹកចិត្តបញ្ចុះអត្រាពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ចំនួន៨០ (ប៉ែតសិប) ភាគរយ ចំពោះ គ.ល.គ. ដែលប្រើប្រាស់គ្រឿងបង្គុំមិនទាន់ផ្សារនិងបាញ់ថ្នាំមានធាតុផ្សំក្នុងស្រុកយ៉ាងតិច២០(ម្ភៃ) ភាគរយ ហើយបំពេញបានលក្ខខណ្ឌ២(ពីរ) ក្នុងចំណោមលក្ខខណ្ឌ៣ (បី) ខាងក្រោម (១) ប្រើប្រាស់គ្រឿងបង្គុំចាប់ពី៦០០ (ប្រាំមួយរយ) បំណែកឡើងទៅក្នុងរថយន្តមួយគ្រឿង (២) មានទុនវិនិយោគចាប់ពី៣៥.០០០.០០០ (សាមសិបប្រាំលាន) ដុល្លារអាម៉េរិកឡើងទៅ(៣) ប្រើប្រាស់កម្លាំងពលកម្មចាប់ពី៥០០(ប្រាំរយ) នាក់ឡើងទៅ
- ទទួលបានការលើកទឹកចិត្តបញ្ចុះអត្រាពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ចំនួន ៩០ (កៅសិប) ភាគរយ ចំពោះ គ.ល.គ. ដែលប្រើប្រាស់គ្រឿងបង្គុំមិនទាន់សង្កត់ពុម្ព ពត់ ផ្សារ និងបាញ់ថ្នាំ មានធាតុផ្សំក្នុងស្រុកយ៉ាងតិច៤០ (សែសិប) ភាគរយ ហើយបំពេញបានលក្ខខណ្ឌ២(ពីរ) ក្នុងចំណោមលក្ខខណ្ឌ៣(បី) ខាងក្រោម(១) ប្រើប្រាស់គ្រឿងបង្គុំចាប់ពី ៧០០(ប្រាំពីររយ) បំណែកឡើងទៅក្នុងរថយន្តមួយគ្រឿង (២) មានទុនវិនិយោគចាប់ពី៤៥.០០០.០០០ (សែសិបប្រាំលាន) ដុល្លារអាម៉េរិកឡើងទៅ(៣) ប្រើប្រាស់កម្លាំងពលកម្មចាប់ពី៦០០(ប្រាំមួយរយ) នាក់ឡើងទៅ។

លក្ខណៈវិនិច្ឆ័យលើការលើកទឹកចិត្តផ្នែកសារពើពន្ធដែលមានចែងនៅក្នុងអនុក្រឹត្យនេះ ជាកម្មវត្ថុនៃការត្រួតពិនិត្យ វាយតម្លៃ និងកែសម្រួលតាមតម្រូវការជាក់ស្តែង ក្រោមការដឹកនាំ និងការសម្របសម្រួលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីលើកជាអនុសាសន៍ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច។

**មាត្រា១៨.-**

គ.ល.គ. មានសិទ្ធិដាក់ការស្នើសុំការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋ ទៅកាន់ **ក.អ.ក.** ឬ **អ.គ.វ.ខ.** ដើម្បីពិនិត្យសម្រេច តាមរយៈយន្តការអន្តរក្រសួង ស្ថាប័ន។

នីតិវិធីសម្រាប់ផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋ លើការនាំចូល និងការប្រើប្រាស់នូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម សម្រាប់គម្រោងវិនិយោគដែលបានចុះបញ្ជីនៅ **ក.អ.ក.** ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង **ក.អ.ក.**។

នីតិវិធីសម្រាប់ផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋ លើការនាំចូល និងការប្រើប្រាស់នូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្មសម្រាប់គម្រោងវិនិយោគដែលបានចុះបញ្ជីនៅ **អ.គ.វ.ខ.** ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។

វិនិយោគិន ឬអ្នកតំណាងដែលមានសិទ្ធិ អាចដាក់ការស្នើសុំជាលាយលក្ខណ៍អក្សរទៅ **ក.អ.ក.** ឬ **អ.គ.វ.ខ.** ដើម្បីសុំការពិនិត្យ និងសម្រេច លើការផ្ទេរ ការលក់ ឬការនាំចេញទៅវិញ តាមរយៈយន្តការអន្តរក្រសួង ស្ថាប័ន នូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម ដែលបាននាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋ ទៅឱ្យវិនិយោគិនផ្សេងទៀតសម្រាប់ប្រើប្រាស់ក្នុង គ.ល.គ. ឬនាំចេញទៅក្រៅប្រទេស។

សម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម ដែលបាននាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋ ដែលប្រើប្រាស់ លក់ ផ្ទេរ ក្នុងគោលដៅផ្សេង ដោយមានការអនុញ្ញាតជាមុនពី **ក.អ.ក.** ឬ **អ.គ.វ.ខ.** វិនិយោគិនត្រូវបង់ពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីគយជាធរមាន។

ក្នុងករណីសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម ដែលបាននាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋ ត្រូវបានប្រើប្រាស់ លក់ ផ្ទេរ ក្នុងគោលដៅផ្សេង ដោយគ្មានការអនុញ្ញាតជាមុនពី **ក.អ.ក.** ឬ **អ.គ.វ.ខ.** វិនិយោគិនត្រូវបង់ពន្ធគយ អាករពិសេស អាករលើតម្លៃបន្ថែម និងពិន័យផ្សេងទៀត អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីគយជាធរមាន។

ចំពោះការបោះបង់ចោលឬកម្ទេចចោល នូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម ដែលបាននាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋ វិនិយោគិន ត្រូវអនុវត្តតាមនីតិវិធីដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

បន្ទាប់ពីទទួលបានសេចក្តីសម្រេចពី ក.អ.ក. ឬ អ.គ.វ.រ.ខ. ឱ្យលក់ ផ្ទេរ ប្រើប្រាស់ក្នុងគោលដៅផ្សេង ក្នុងរយៈពេល ២៨(ម្ភៃប្រាំបី)ថ្ងៃ វិនិយោគិនមានកាតព្វកិច្ចបង់ពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម និង/ឬ ពិន័យផ្សេងៗ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីគយជាធរមាន។

ការខកខានឬការយឺតយ៉ាវចំពោះការបង់ពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម និង/ឬពិន័យ ដូចមានចែងក្នុងមាត្រានេះ វិនិយោគិនត្រូវរងនូវវិធានការរដ្ឋបាល អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៤
## ការផ្តល់សេវាថែទាំវិនិយោគ

**មាត្រា១៩.-**

ក.អ.ក. ឬ អ.គ.វ.រ.ខ. ត្រូវផ្តល់សេវាថែទាំវិនិយោគ ដូចខាងក្រោម៖

១- សិក្សាវាយតម្លៃស្ថានភាព និងស្វែងយល់ពីវឌ្ឍនភាព តម្រូវការជាក់ស្តែង និងបញ្ហាប្រឈមរបស់គម្រោងវិនិយោគឬរបស់វិនិយោគិន តាមរយៈការប្រមូលព័ត៌មានដែលផ្តល់ដោយវិនិយោគិន។

២- រៀបចំជំនួបរវាងតំណាងក្រសួងស្ថាប័ននិងវិនិយោគិនពាក់ព័ន្ធ ក្នុងគោលបំណងផ្សព្វផ្សាយ តម្រង់ទិស និងបង្កើនការយល់ដឹងពីបច្ចុប្បន្នភាពនៃការវិវត្តគោលនយោបាយ ការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីពាក់ព័ន្ធនឹងការវិនិយោគ។

៣- ពិគ្រោះយោបល់និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត មន្ទីរ និងអង្គភាពពាក់ព័ន្ធដើម្បីទទួលយកនូវការយល់ព្រម ការអនុញ្ញាត អាជ្ញាបណ្ណ លិខិតអនុញ្ញាត ឬបញ្ជិកានានា និងទិដ្ឋាការចេញចូល និងស្នាក់នៅរបស់វិនិយោគិន។

៤- រៀបចំកម្មវិធីផ្គូផ្គងវិនិយោគិនទាំងក្នុងប្រទេសនិងបរទេស សំដៅលើកកម្ពស់ការធ្វើសន្ទានកម្មខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងស្រុក។

៥- រៀបចំជំនួបរវាងតំណាងក្រសួង ស្ថាប័នរដ្ឋបាលរាជធានី ខេត្ត មន្ទីរ និងអង្គភាព និងវិនិយោគិនពាក់ព័ន្ធ ក្នុងគោលបំណងផ្សព្វផ្សាយតម្រង់ទិស និងបង្កើនការយល់ដឹងពីការរៀបចំប្រព័ន្ធទិន្នន័យសម្រាប់បម្រើឱ្យការធ្វើសន្ទានកម្មខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងស្រុក និងការផ្តល់សេវាថែទាំវិនិយោគទូទៅ។

៦- សម្របសម្រួលជាមួយគម្រោងវិនិយោគដែលមានស្រាប់ ដើម្បីជំរុញការទាក់ទាញក្រុមហ៊ុនផ្គត់ផ្គង់ធាតុចូលផលិតកម្មរបស់គម្រោងវិនិយោគទាំងនោះមកវិនិយោគនៅកម្ពុជា ក្នុងទិសដៅធ្វើឱ្យកាន់តែស៊ីជម្រៅនូវសន្ទានកម្មឧស្សាហកម្មប្រតិគមន៍ និងឧស្សាហកម្មអនុគមន៍។

៧- ពិគ្រោះយោបល់លើការស្វែងរកទីតាំងយុទ្ធសាស្ត្រនិងសក្តានុពលសម្រាប់គម្រោងវិនិយោគ ឬការពង្រីកគម្រោងវិនិយោគដែលអាចតភ្ជាប់ទៅនឹងប៉ូលសេដ្ឋកិច្ចនិងច្រករបៀងសេដ្ឋកិច្ចសំខាន់ៗនៅក្នុងប្រទេសកម្ពុជា អនុតំបន់ទន្លេមេគង្គ និងតំបន់អាស៊ាន។

៨- ពិគ្រោះយោបល់លើការអភិវឌ្ឍធនធានមនុស្ស ការស្រាវជ្រាវនិងអភិវឌ្ឍន៍ និងនវានុវត្តន៍។

៩- សម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធលើការគាំទ្រហិរញ្ញវត្ថុដល់វិនិយោគិន។

១០-ពិគ្រោះយោបល់ជាមួយវិនិយោគិន លើបញ្ហាប្រឈមនានា និងស្វែងរកលទ្ធភាពផ្តល់ជាដំណោះស្រាយដើម្បីទប់ស្កាត់វិវាទវិនិយោគដែលអាចកើតឡើងជាយថាហេតុ។

១១-ផ្តល់ការពិគ្រោះយោបល់លើយន្តការដោះស្រាយវិវាទដែលកើតចេញពីការអនុវត្តគម្រោងវិនិយោគស្របតាមមាត្រា៣៦ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

**ក.អ.ក.** ឬ **អ.គ.វ.រ.ខ.** ត្រូវរៀបចំយន្តការផ្តល់សេវាថែទាំវិនិយោគ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសម្រួលវិនិយោគ សំដៅបង្កើនទំនុកចិត្ត និងស្វែងរកលទ្ធភាពដោះស្រាយបញ្ហាប្រឈមរបស់វិនិយោគិនក្នុងគ្រប់ដំណាក់កាលនៃការអនុវត្តគម្រោងវិនិយោគ ដែលនឹងធានានូវផលប្រយោជន៍របស់គ្រប់ភាគីពាក់ព័ន្ធ ការប្រកួតប្រជែងស្មើភាព និងបរិយាកាសវិនិយោគអំណោយផល។

**មាត្រា២០.-**

ការផ្តល់សេវាថែទាំវិនិយោគ ត្រូវធ្វើឡើងតាមរយៈយន្តការអន្តរក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត មន្ទីរ និងអង្គភាព ដែលជាសេនាធិការរបស់ **ក.អ.ក.** ឬ **អ.គ.វ.រ.ខ.** ដែលត្រូវបង្កើតឡើងតាមរយៈសេចក្តីសម្រេចរបស់ **ក.អ.ក.** ឬ **អ.គ.វ.រ.ខ.**។

**ក.អ.ក.** ឬ **អ.គ.វ.រ.ខ.** ត្រូវចាត់អ្នកសម្របសម្រួលឱ្យបំពេញតួនាទីជា "មន្ត្រីបង្គោល" ដើម្បីដឹកនាំយន្តការអន្តរក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត មន្ទីរ និងអង្គភាពនេះ ដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ។

ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត មន្ទីរ និងអង្គភាពពាក់ព័ន្ធ ត្រូវចាត់តំណាងដែលមានសិទ្ធិសម្រេចដើម្បីចូលរួមអនុវត្តយន្តការអន្តរក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត មន្ទីរ និងអង្គភាព នេះ។

**មាត្រា២១.-**

វិនិយោគិនអាចស្នើសុំសេវាថែទាំវិនិយោគពីយន្តការអន្តរក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត មន្ទីរ និងអង្គភាពដោយត្រូវបញ្ជូនការស្នើជាលាយលក្ខណ៍អក្សរមក **ក.អ.ក.** ឬ **អ.គ.វ.រ.ខ.** ដោយកំណត់និងបញ្ជាក់ឱ្យបានច្បាស់នូវបញ្ហាប្រឈមនិងវិធានការជាក់លាក់ដែលប៉ះពាល់ដល់ការអនុវត្តគម្រោងវិនិយោគរបស់ខ្លួនទៅតាមទម្រង់ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១០ នៃអនុក្រឹត្យនេះ។

ក្រោយពីទទួលបានការស្នើសុំថែទាំវិនិយោគ **ក.អ.ក.** ឬ **អ.គ.វ.រ.ខ.** ត្រូវឆ្លើយតបដោយបញ្ជាក់អំពីការសម្រេចរៀបចំកាលវិភាគនិងកម្មវិធីការងារសម្រាប់សិក្សា វាយតម្លៃ និងកំណត់បញ្ហាប្រឈម។

ក្នុងករណីចាំបាច់ **ក.អ.ក.** ឬ **អ.គ.វ.រ.ខ.** ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត មន្ទីរ និងអង្គភាពពាក់ព័ន្ធ ដើម្បីជួយដោះស្រាយបញ្ហាប្រឈម ឬក៏អាចអញ្ជើញវិនិយោគិនឱ្យជួបផ្ទាល់ជាមួយក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត មន្ទីរ និងអង្គភាពពាក់ព័ន្ធ ដើម្បីពិភាក្សារកដំណោះស្រាយផងដែរ។

## ជំពូកទី៥
## ការទិញ ការលក់ ឬការរួមបញ្ចូលគ្នានៃគម្រោងវិនិយោគ

**មាត្រា២២._**

គម្រោងវិនិយោគអាចត្រូវបានទិញ លក់ ឬរួមបញ្ចូលគ្នា ដោយបន្តទទួលបានការលើកទឹកចិត្ត ការធានានិងការការពារលើការវិនិយោគ និងបន្តបំពេញកាតព្វកិច្ចទាំងឡាយ ដោយអនុលោមទៅតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យនេះ ប្រសិនបើការទិញ ការលក់ ឬការរួមបញ្ចូលគ្នា មិនត្រូវបានហាមឃាត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬមិនត្រូវបានកម្រិតដោយវិញ្ញាបនបត្រចុះបញ្ជីឬកិច្ចសន្យាសម្បទានផ្សេងទៀត។

គម្រោងវិនិយោគអាចត្រូវបានទិញ លក់ ឬរួមបញ្ចូលគ្នា ដោយបុគ្គលជាវិនិយោគិន អនុលោមតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ក្នុងករណីដែលបុគ្គលដែលមិនទាន់ត្រូវបានចាត់ទុកជាវិនិយោគិន ចង់ទិញ ឬរួមបញ្ចូលគ្នានៃគម្រោងវិនិយោគ បុគ្គលនោះត្រូវស្នើសុំជាលាយលក្ខណ៍អក្សរទៅ **ក.អ.ក.** ឬ **អ.គ.វ.វ.ខ.** តាមនីតិវិធីជាធរមាន។

គម្រោងវិនិយោគពីរ ឬច្រើន អាចត្រូវបានបញ្ចូលគ្នាជាគម្រោងវិនិយោគតែមួយ ដោយអាចរក្សានូវឈ្មោះគម្រោងវិនិយោគដើមណាមួយ ឬបង្កើតឈ្មោះគម្រោងវិនិយោគថ្មី ដោយបន្តទទួលបានការលើកទឹកចិត្ត ការធានានិងការការពារលើការវិនិយោគ និងបន្តបំពេញកាតព្វកិច្ចទាំងឡាយ។

ការរួមបញ្ចូលគ្នានៃគម្រោងវិនិយោគ មិនធ្វើឱ្យបាត់បង់បុគ្គលភាពគតិយុត្តនៃវិនិយោគិនដែលអនុវត្តគម្រោងវិនិយោគនៅមុនការរួមបញ្ចូលគ្នានៃគម្រោងវិនិយោគទេ លើកលែងតែវិនិយោគិននោះជានីតិបុគ្គលដែលត្រូវបានលុបចោល ដោយអនុលោមទៅតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

រាល់ការទិញ ការលក់ ឬរួមបញ្ចូលគ្នាគម្រោងវិនិយោគមួយ ឬច្រើន ដែលខកខានមិនបានសុំការចុះបញ្ជីនៅ **ក.អ.ក.** ឬ **អ.គ.វ.វ.ខ.**ដោយអនុលោមតាមជំពូកទី៥នៃអនុក្រឹត្យនេះ បុគ្គលដែលជាអ្នកទិញនៅក្រោយការទិញ ការលក់ឬរួមបញ្ចូលគ្នា ត្រូវបាត់បង់សិទ្ធិក្នុងការទទួលបានការលើកទឹកចិត្ត និងការធានានិងការការពារលើការវិនិយោគ។

**មាត្រា២៣._**

បុគ្គលដែលមានបំណងទិញឬលក់គម្រោងវិនិយោគ ត្រូវដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរមក **ក.អ.ក.** ឬ **អ.គ.វ.វ.ខ.** ដោយភ្ជាប់មកជាមួយនូវឯកសារគាំទ្រចាំបាច់មួយចំនួន ដូចខាងក្រោម៖

១- ពាក្យស្នើសុំដែលចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាលឬអភិបាលដែលមានសិទ្ធិ។

២- សេចក្តីសម្រេចរបស់វិនិយោគិនជាអ្នកលក់និងបុគ្គលជាអ្នកទិញ។ ក្នុងករណីវិនិយោគិនជានីតិបុគ្គល សេចក្តីសម្រេចនោះត្រូវធ្វើឡើងដោយម្ចាស់ភាគហ៊ុន។

៣- សេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលដែលមានសិទ្ធិដោយភ្ជាប់ជាមួយនូវសេចក្តីចម្លងលក្ខន្តិកៈក្រុមហ៊ុនមេនៅក្រៅប្រទេសដែលត្រូវបានបកប្រែជាខេមរភាសា ឬជាភាសាអង់គ្លេស ហើយឯកសារទាំងអស់នេះមានប្រថាប់ត្រាក្រុមហ៊ុន ការបញ្ជាក់ពីមេធាវីឬសារការី ក្នុងករណីម្ចាស់ភាគហ៊ុនជានីតិបុគ្គលនៅក្រៅប្រទេស។

៤- កិច្ចព្រមព្រៀងស្តីពីការទិញឬការលក់គម្រោងវិនិយោគ។

៥- លិខិតបញ្ជាក់ការទទួលខុសត្រូវនូវបំណុលពន្ធរដ្ឋនិងបំណុលផ្សេងៗ។

៦- លិខិតប្រគល់-ទទួលបញ្ជីសម្ភារៈសារពើភណ្ឌដែលទទួលបានការលើកទឹកចិត្តពី **ក.អ.ក.** ឬ **អ.គ.វ.ខ.**។

៧- អត្តសញ្ញាណបណ្ណ "សញ្ជាតិខ្មែរ" ឬលិខិតឆ្លងដែន "បរទេស" (សមាជិកថ្មី)។

បុគ្គលដែលមានបំណងរួមបញ្ចូលនូវគម្រោងវិនិយោគ ត្រូវដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរមក **ក.អ.ក.** ឬ **អ.គ.វ.ខ.** ដោយភ្ជាប់មកជាមួយនូវឯកសារគាំទ្រចាំបាច់មួយចំនួន ដូចខាងក្រោម៖

១- ពាក្យស្នើសុំដែលចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាលឬអភិបាលដែលមានសិទ្ធិ។

២- សេចក្តីសម្រេចរបស់វិនិយោគិនដែលជាម្ចាស់គម្រោងវិនិយោគ។ ក្នុងករណីវិនិយោគិនជានីតិបុគ្គល សេចក្តីសម្រេចនោះត្រូវធ្វើឡើងដោយម្ចាស់ភាគហ៊ុន។

៣- សេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលដែលមានសិទ្ធិ ដោយភ្ជាប់ជាមួយនូវសេចក្តីចម្លងលក្ខន្តិកៈក្រុមហ៊ុនមេនៅក្រៅប្រទេសដែលត្រូវបានបកប្រែជាខេមរភាសា ឬជាភាសាអង់គ្លេស ហើយឯកសារទាំងអស់នេះមានប្រថាប់ត្រាក្រុមហ៊ុន ការបញ្ជាក់ពីមេធាវីឬសារការី ក្នុងករណីម្ចាស់ភាគហ៊ុនជានីតិបុគ្គលនៅក្រៅប្រទេស។

៤- ឈ្មោះវិនិយោគិនដែលត្រូវបន្តអនុវត្តគម្រោងវិនិយោគនៅក្រោយការរួមបញ្ចូលគ្នា។

៥- កិច្ចព្រមព្រៀងរួមបញ្ចូលគ្នា។

៦- លក្ខន្តិកៈក្រុមហ៊ុនមានសុពលភាព ដែលជានីតិបុគ្គលអនុវត្តគម្រោងវិនិយោគដែលត្រូវរួមបញ្ចូលគ្នា។

៧- លិខិតបញ្ជាក់ការទទួលខុសត្រូវនូវបំណុលពន្ធរដ្ឋនិងបំណុលផ្សេងៗ។

៨- លិខិតប្រគល់-ទទួលបញ្ជីសម្ភារៈសារពើភណ្ឌដែលទទួលបានការលើកទឹកចិត្តពី **ក.អ.ក.** ឬ **អ.គ.វ.ខ.**។

៩- អត្តសញ្ញាណបណ្ណ "សញ្ជាតិខ្មែរ" ឬលិខិតឆ្លងដែន "បរទេស" (សមាជិកថ្មី)។

គម្រោងវិនិយោគត្រូវបានចាត់ទុកថាបានទិញ លក់ ឬត្រូវបានរួមបញ្ចូលគ្នា នៅក្រោយទទួលបានការអនុញ្ញាតជាផ្លូវការ និងការទទួលស្គាល់នូវលក្ខន្តិកៈថ្មីរបស់នីតិបុគ្គលដែលបន្តអនុវត្តគម្រោងវិនិយោគពី **ក.អ.ក.** ឬ **អ.គ.វ.ខ.**។

វិនិយោគិនដែលទទួលអនុវត្តគម្រោងវិនិយោគបន្ត តាមរយៈការទិញ ការលក់ ឬការរួមបញ្ចូលគ្នានៃគម្រោងវិនិយោគ ដោយអនុលោមតាមជំពូកទី៥នៃអនុក្រឹត្យនេះ ត្រូវទទួលបន្តនូវសិទ្ធិនិងកាតព្វកិច្ចទាំងឡាយដែលមានអត្ថិភាពចំពោះគម្រោងវិនិយោគ។

## ជំពូកទី៦

## ការលុបគម្រោងវិនិយោគ

**មាត្រា២៤._**

ក្នុងករណីការលុបគម្រោងវិនិយោគ ដោយមូលហេតុអលទ្ធភាពក្នុងការអនុវត្តគម្រោងវិនិយោគបន្តទៀត ដូចមានចែងនៅក្នុងចំណុច១នៃមាត្រា៣១ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា វិនិយោគិនត្រូវដាក់ពាក្យសុំលុបគម្រោងវិនិយោគដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលមានសិទ្ធិ ទៅ **ក.អ.ក.** ឬ **អ.គ.វ.ខ.** ដោយភ្ជាប់មកជាមួយនូវឯកសារគាំទ្រមួយចំនួន ដូចខាងក្រោម៖

១- ពាក្យស្នើសុំដែលចុះហត្ថលេខាដោយវិនិយោគិនឬអ្នកតំណាងដែលមានសិទ្ធិ។ ក្នុងករណីវិនិយោគិនជានីតិបុគ្គល ពាក្យស្នើសុំត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល។

២- សេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលដែលមានសិទ្ធិ ដោយភ្ជាប់ជាមួយនូវសេចក្តីចម្លងលក្ខន្តិកៈក្រុមហ៊ុនមេនៅក្រៅប្រទេសដែលត្រូវបានបកប្រែជាខេមរភាសា ឬជាភាសាអង់គ្លេស ហើយឯកសារទាំងអស់នេះមានប្រថាប់ត្រាក្រុមហ៊ុន ការបញ្ជាក់ពីមេធាវីឬសារការី ក្នុងករណីម្ចាស់ភាគហ៊ុនជានីតិបុគ្គលនៅក្រៅប្រទេស។

៣- លក្ខន្តិកៈមានសុពលភាពរបស់នីតិបុគ្គល។

៤- ឯកសារបញ្ជាក់អំពីស្ថានភាពបំណុលចំពោះបុគ្គលិក កម្មករ-និយោជិត។

៥- របាយការណ៍ហិរញ្ញវត្ថុសង្ខេបសម្រាប់រយៈពេល ៣(បី)ឆ្នាំចុងក្រោយ គិតត្រឹមកាលបរិច្ឆេទនៃការសម្រេចការបញ្ចប់ការអនុវត្តគម្រោងវិនិយោគ។

៦- ឯកសារគាំទ្រផ្សេងទៀតដែលអាចបញ្ជាក់អំពីស្ថានភាពនៃការអនុវត្តគម្រោងវិនិយោគ ប្រសិនបើមាន។

ក្នុងករណីការលុបគម្រោងវិនិយោគ ដោយមូលហេតុនីតិបុគ្គលដែលអនុវត្តគម្រោងវិនិយោគត្រូវបានរំលាយតាមការព្រមព្រៀងជាឯកច្ឆន្ទរបស់សហកម្មសិទ្ធិករទូទៅ ដូចមានចែងនៅក្នុងចំណុច២នៃមាត្រា៣១ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា វិនិយោគិនត្រូវដាក់ពាក្យសុំលុបគម្រោងវិនិយោគដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលមានសិទ្ធិទៅ **ក.អ.ក.** ឬ **អ.គ.វ.រ.ខ.** ដោយភ្ជាប់មកជាមួយនូវឯកសារគាំទ្រមួយចំនួន ដូចខាងក្រោម៖

១- ពាក្យស្នើសុំដែលចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល ឬអ្នកតំណាងដែលមានសិទ្ធិ។

២- សេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលដែលមានសិទ្ធិ ដោយភ្ជាប់ជាមួយនូវសេចក្តីចម្លងលក្ខន្តិកៈក្រុមហ៊ុនមេនៅក្រៅប្រទេសដែលត្រូវបានបកប្រែជាខេមរភាសា ឬជាភាសាអង់គ្លេស ហើយឯកសារទាំងអស់នេះមានប្រថាប់ត្រាក្រុមហ៊ុន ការបញ្ជាក់ពីមេធាវីឬសារការី ក្នុងករណីម្ចាស់ភាគហ៊ុនជានីតិបុគ្គលនៅក្រៅប្រទេស។

៣- កំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសម្រេចរំលាយនីតិបុគ្គល។

៤- លក្ខន្តិកៈមានសុពលភាពរបស់នីតិបុគ្គល។

៥- ឯកសារបញ្ជាក់អំពីស្ថានភាពបំណុលចំពោះបុគ្គលិក កម្មករ-និយោជិត។

៦- របាយការណ៍ហិរញ្ញវត្ថុសង្ខេបសម្រាប់រយៈពេល ៣ (បី)ឆ្នាំចុងក្រោយ គិតត្រឹមកាលបរិច្ឆេទនៃការសម្រេចការបញ្ចប់ការអនុវត្តគម្រោងវិនិយោគ។

៧- ឯកសារគាំទ្រផ្សេងទៀតដែលអាចបញ្ជាក់អំពីស្ថានភាពនៃការអនុវត្តគម្រោងវិនិយោគ ប្រសិនបើមាន។

ក្នុងករណីការលុបគម្រោងវិនិយោគ ដោយមូលហេតុនីតិបុគ្គលដែលអនុវត្តគម្រោងវិនិយោគត្រូវបានរំលាយដោយសេចក្តីសម្រេចរបស់តុលាការ ដូចមានចែងនៅក្នុងចំណុច២នៃមាត្រា៣១ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា វិនិយោគិនត្រូវដាក់ពាក្យសុំលុបគម្រោងវិនិយោគដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលមានសិទ្ធិទៅ **ក.អ.ក.** ឬ **អ.គ.វ.រ.ខ.** ដោយភ្ជាប់មកជាមួយនូវសេចក្តីសម្រេចស្ថាពររបស់តុលាការអំពីការរំលាយនីតិបុគ្គល។

ក្នុងករណីការលុបគម្រោងវិនិយោគ ដោយមូលហេតុមិនបានអនុវត្តកាតព្វកិច្ចដែលបានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដូចមានចែងនៅក្នុងចំណុច៣នៃមាត្រា៣១ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក.អ.ក. ឬ អ.គ.វ.ស.ខ. មានឆន្ទានុសិទ្ធិក្នុងការលុបគម្រោងវិនិយោគ ប្រសិនបើ៖

១- វិនិយោគិន មិនបានបំពេញលក្ខខណ្ឌនានាដែលមានចែងក្នុងវិញ្ញាបនបត្រចុះបញ្ជី។ ករណីនេះមិនរាប់បញ្ចូលនូវការមិនបានបំពេញលក្ខខណ្ឌ ដោយសារប្រធានសក្តិទេ។ ឬ

២- វិនិយោគិនមិនបានចាប់ផ្តើមអនុវត្តគម្រោងវិនិយោគរបស់ខ្លួន ក្នុងរយៈពេល ១២ (ដប់ពីរ)ខែ បន្ទាប់ពីទទួលបានវិញ្ញាបនបត្រចុះបញ្ជី។ ករណីនេះមិនរាប់បញ្ចូលនូវការមិនបានអនុវត្តគម្រោងវិនិយោគដោយសារប្រធានសក្តិ ឬការអនុវត្តកិច្ចសន្យាសម្បទាន ដែលរយៈពេលនឹងកំណត់ជាក់ស្តែងតាមការព្រមព្រៀងនៅក្នុងកិច្ចសន្យា។ ឬ

៣- ការអនុវត្តគម្រោងវិនិយោគជាក់ស្តែងខុសពីមុខសញ្ញាវិនិយោគដែលបានចុះបញ្ជី។

ក្នុងករណីការលុបគម្រោងវិនិយោគ ដោយមូលហេតុតាមការស្នើរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ ឬតាមការស្នើរបស់វិនិយោគិន ដូចមានចែងនៅក្នុងចំណុច៤នៃមាត្រា៣១ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងស្ថាប័នពាក់ព័ន្ធ ឬវិនិយោគិន ត្រូវដាក់ពាក្យសុំលុបគម្រោងវិនិយោគទៅ ក.អ.ក. ឬ អ.គ.វ.ស.ខ. ដើម្បីពិនិត្យ និងសម្រេច ដោយភ្ជាប់មកជាមួយនូវសំណុំឯកសារបញ្ជាក់ ដូចខាងក្រោម៖

១- ការណ៍ដែលបង្កផលប៉ះពាល់ធ្ងន់ធ្ងរ ជាអាទិ៍ ដល់បរិស្ថាន ឬសន្តិសុខជាតិ ឬផលប្រយោជន៍សាធារណៈ ឬសុខុមាលភាពប្រជាពលរដ្ឋ។ ឬ

២- ការណ៍ដែលវិនិយោគិនគេចវេះការបំពេញកាតព្វកិច្ចសារពើពន្ធ។ ឬ

៣- ការណ៍ដែលវិនិយោគិនមិនបានបំពេញកាតព្វកិច្ចនានាដែលមានចែងក្នុងវិញ្ញាបនបត្រចុះបញ្ជី។ ករណីនេះមិនរាប់បញ្ចូលនូវការមិនបានបំពេញកាតព្វកិច្ចដោយសារប្រធានសក្តិទេ។ ឬ

៤- ការណ៍ដែលគម្រោងវិនិយោគបានបាត់បង់សិទ្ធិប្រើប្រាស់ទីតាំង។

គម្រោងវិនិយោគ ត្រូវបានចាត់ទុកថាបានលុប នៅពេលដែល ក.អ.ក. ឬ អ.គ.វ.ស.ខ. បញ្ជាក់អំពីការលុបគម្រោងវិនិយោគ តាមរយៈលិខិតជាលាយលក្ខណ៍អក្សរ។

**មាត្រា២៥.-**

ក្នុងករណីគម្រោងវិនិយោគត្រូវបានលុប វិនិយោគិនអាចផ្ទេរទ្រព្យសម្បត្តិដែលនៅសេសសល់ទៅក្រៅប្រទេស ឬប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមនីតិវិធីនិងខ្លឹមសារដូចមានចែងក្នុងមាត្រា១៨ នៃអនុក្រឹត្យនេះ។

**មាត្រា២៦.-**

ទោះបីគម្រោងវិនិយោគត្រូវបានលុបក៏ដោយ វិនិយោគិនមិនអាចរួចផុតពីកាតព្វកិច្ចសារពើពន្ធនិងកាតព្វកិច្ចដទៃផ្សេងៗទៀត អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

# ជំពូកទី៧

# អវសានប្បញ្ញត្តិ

**មាត្រា២៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៩ កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី ១÷ បញ្ជីអវិជ្ជមាន

នៃអនុក្រឹត្យលេខ១៣៩ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

**សកម្មភាពវិនិយោគ ឬ ក្រុមសកម្មភាពវិនិយោគដែលមិនទទួលបាននូវការលើកទឹកចិត្ត**

